# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ដឹកនាំប្រតិភូក្រុមការងារចុះចែកទឹក ដល់ប្រជាពលរដ្ឋនៅខេត្តកំពត និងខេត្តកែប



ក្នុងគោលបំណងរួមចំណែកជួយរំលែកការលំបាកចំពោះមុខរបស់ប្រជាពលរដ្ឋ ដែលទទួលរងគ្រោះដោយបាតុភូតធម្មជាតិរាំងស្ងួត និងរលកកំដៅ ហើយកំពុងប្រឈមនិងកង្វះខាតទឹកស្អាតបរិភោគ និងប្រើប្រាស់ ក្នុងជីវភាពប្រចាំថ្ងៃ និងយោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងយុទ្ធនាការចែកទឹកទូទាំងប្រទេស នៅរសៀលថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៦ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានខេត្ត កំពត បានដឹកនាំគណៈប្រតិភូក្រសួង និងសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត អញ្ជើញសំណេះសំណាល និងផ្តល់ទឹកបរិភោគ និងទឹកប្រើប្រាស់ដល់ប្រជាពលរដ្ឋស្ថិតក្នុងភូមិព្រានទុំ ឃុំស្រែជាខាងជើង ស្រុកដងទុង ខេត្តកំពត ដែលកំពុងប្រឈមនិងភាពខ្វះខាតទឹក ក្នុងជីវភាពប្រចាំថ្ងៃ ។

មានប្រសាសន៍សណេះសំណាលនាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានពាំនាំនូវការសាកសួរសុខទុក្ខ ពីសំណាក់**សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចមានការខ្វល់ខ្វាយជាខ្លាំង ចំពោះសុខទុក្ខប្រជាពលរដ្ឋទូទាំងប្រទេស ជាពិសេស ក្នុងដំណាក់កាលដែលប្រជាពលរដ្ឋយើងកំពុងរងផលប៉ះពាល់ នូវភាពរាំងស្ងួត និងរលកកំដៅនាពេលបច្ចុប្បន្ននេះ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា:ការចែកចាយទឹកនេះ ជាយុទ្ធនាការទូទាំងប្រទេស ដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** **បាន**ធ្វើការណែនាំជាទូទៅ ហើយក្នុងនាម

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឯកឧត្តម ក៏បានដាក់បញ្ជា ជាលេខល័ក្សអក្សរ ដល់ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួង ដែលស្ថិតក្នុងក្រុមការងារថ្នាក់ជាតិ រដ្ឋាករទឹកស្វយ័ត និងមន្ទីរឧស្សាហកម្មខេត្តទាំងអស់ សហការជាមួយអាជ្ញាធរដែនដីអនុវត្តយុទ្ធនាការនេះ ឱ្យបានល្អប្រសើរតាមតំបន់គោលដៅដែលកំពុងទទួលរងនូវការខ្វះខាតទឹក ។ ក្នុងនាមជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានខេត្តកំពត ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណដល់ក្រុមហ៊ុន **ជីប ម៉ុង** ដែលបានជួយជារថយន្តដឹកទឹកចំនួន ០៥ គ្រឿង ហើយកំពុងពិនិត្យលទ្ធភាពជួយចំនួន០៥គ្រឿងទៀត ។ ទាក់ទង និងចំណុចនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានអំពាវនាវដល់សប្បុរសជននានា បន្តជួយគ្រប់មធ្យោបាយតាមលទ្ធភាពជាក់ស្តែង ជាពិសេសប្រឈមការខ្វះខាតរថយន្តដឹកជញ្ជូនទឹក ។ ស្ថិតក្នុងឱកាសនោះដែរ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានណែនាំឱ្យមន្ត្រីជំនាញស្វែងរកទីតាំងសមស្របដែលមានប្រភពទឹកក្រោមដី ដើម្បីខួងអណ្តូង បូមទឹកចែកជូនប្រជាពលរដ្ឋ ដែលនៅឆ្ងាយពីប្រភពទឹក និងមិនមានទឹកស្អាតចូលដល់ ។ ដែលដំណាក់កាលដំបូង ឯកឧត្តម បានសម្រេចឱ្យខួងអណ្តូងនៅ នៅស្រុកដងទុងមួយ និងស្រុកកំពង់ត្រាចមួយ បើលទ្ធផលល្អ យើងនឹងបន្តធ្វើនៅកន្លែងដ៏ទៃទៀត ដោយឯកឧត្តមនឹងចេញថវិកាផ្ទាល់ខ្លួន និងស្វែងរកប្រភពថវិកាពីសប្បុរសជនខ្លះ ។ ដោយឡែក ចំពោះការផ្គត់ផ្គង់ទឹកបន្តទៀត ក្នុងយុទ្ធនាការនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើឱ្យពិនិត្យលទ្ធភាពឱ្យខ្ពស់ជាងនេះ គឺបូមទឹកស្អាតពីរដ្ឋាករទឹករដ្ឋ និងឯកជន ដែលជាជំនួយឧបត្ថម្ភ ហើយបើលើសលទ្ធភាពយើងនឹងចំណាយលុយទិញពីអង្គភាពនោះបន្ថែម ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានទឹកស្អាតប្រើប្រាស់ ជៀសវាងការប៉ះពាល់សុខភាពជាយថាហេតុ ។



បន្ទាប់មក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ និងប្រតិភូបានបន្តដំណើរចុះពិនិត្យ មើលការដ្ឋានសាងសង់ទំនប់បង្ហៀរទឹកត្រពាំងក្ពារ ស្ថិតនៅឃុំស្រែជាខាងជើង ស្រុកដងទុងខេត្តកំពត ដែលជាការយកចិត្តទុកដាក់របស់អជ្ញាធរខេត្តសម្រាប់ជាប្រយោជន៍សាធារណៈ ។

ដោយឡែក នៅព្រឹកថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ បន្ទាប់ពីបញ្ចប់ការប្រារព្ធពិធីអបអរសាទរខួបទី១៥៣ ទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទក្រហម ០៨ ឧសភា ឆ្នាម២០១៦ រួចមក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រួមនិងប្រតិភូ បានអញ្ជើញចុះចែកទឹកដល់ប្រជាពលរដ្ឋ ស្ថិតនៅក្រុងកែប ដោយទទួលបានសាទរ និងរីករាយយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋ ។ ក្នុងឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា: ឯកឧត្តម នឹងរិះរកគ្រប់មធ្យោបាយ និងវិធានការនានា ដើម្បីជួយដល់ប្រជាពលរដ្ឋគ្រប់ពេលវេលា និងកោតសរសើរចំពោះកិច្ចសហការដ៏ល្អនៃគ្រប់សមាសភាពក្រុមការងារទាំងអស់។


TRUCK PREAH MONIVONG NATIONAL PARK




POLICE









